# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សីលី ម៉ាតាំង
# ទួលក្រសាំង ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩
## គ្រួសារដែលរស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ៤,១៣-១៨**

បងប្អូនអើយ យើងចង់ឲ្យបងប្អូនជ្រាបយ៉ាងច្បាស់ខ អំពីអស់អ្នកដែលបានស្លាប់គផុតទៅហើយ ដើម្បីកុំឲ្យបងប្អូនព្រួយចិត្តដូចអ្នកឯទៀតៗ ដែលគ្មានសេចក្ដីសង្ឃឹមនោះឡើយ។ ១ ថស ៤,១៣

**ដំណឹងល្អ៖ លូកា ៤,១៦-៣០**

ព្រះយេស៊ូមានព្រះបន្ទូលទៅគេថា៖ «ប្រហែលជាអ្នករាល់គ្នាចង់យកសុភាសិតដែលថែងថា "គ្រូពេទ្យអើយ ចូរមើលជំងឺរបស់ខ្លួនឲ្យជាសិនទៅ" មកផ្ទាញ់ផ្ទាលខ្ញុំទេដឹង! ឬមួយអ្នករាល់គ្នាចង់និយាយមកខ្ញុំទៀតថា "យើងឮគេនិយាយអំពីកិច្ចការទាំងអស់ ដែលអ្នកធ្វើនៅក្រុងកាផានុម ចូរធ្វើការដដែលនៅទីនេះជាស្រុកកំណើតរបស់អ្នក ឲ្យយើងឃើញផង!"»។ លក ៤,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងរួមគ្នាជាមួយធាតុសន្ត លូវីស និងសន្តី ហ្សីលីម៉ាតាំង ពីក្មេង លូវីស គាត់ចង់ធ្វើជាបូជាចារ្យ និង ហ្សីលី គាត់ចង់ធ្វើជាបងស្រី ប៉ុន្តែនៅពេលគេចាប់ផ្ដើមត្រៀមខ្លួនចូលទេវគេថា លូវីស ធ្វើបូជាចារ្យមិនបាន និង ហ្សីលី ធ្វើជាបងស្រីមិនបាន។ មានថ្ងៃមួយ ទាំង២នាក់ដើរលើស្ពានមួយនិងឃើញមុខគ្នាទៅវិញទៅមក គេចាប់ផ្ដើមស្រឡាញ់គ្នានិងគេយល់ថាគេនឹងរៀបការធ្វើជាប្ដីប្រពន្ធនិងគ្នា។ ៣ខែក្រោយមក គេរៀបការជាមួយគ្នាមែន រួចហើយគេគិតអំពីគម្រោងការណ៍របស់ព្រះជាម្ចាស់សម្រាប់មនុស្ស ព្រះជាម្ចាស់ចង់ឲ្យមនុស្សមានកូនយ៉ាងច្រើន ដូច្នេះគេចង់មានកូនច្រើន ដើម្បីឲ្យកូនស្គាល់ព្រះជាម្ចាស់និងនៅថ្ងៃអនាគត មានជីវិតអស់កល្បជានិច្ចរួមជាមួយព្រះជាម្ចាស់។ គេមានកូន៩នាក់ ក្នុងចំណោមនោះមាន៤នាក់ដែលស្លាប់ក្នុងកុមារភាព និងកូនស្រី៥នាក់ដែលនៅរស់ជាដូនជីទាំងប្រាំ។ គ្រួសារនេះ ជាគ្រួសារធម្មតាដែលរស់នៅជាគ្រួសារដូចយើង ប៉ុន្តែជាគ្រួសារពិសេសដោយសារបានភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងរបៀបអស្ចារ្យ។ ទាំង២នាក់ ព្រះសហគមន៍បានទទួលស្គាល់ជាសន្ត សន្តី នៅឆ្នាំ២០១៥ថ្មីៗនេះ។ ហ្សីលីពេលគាត់អាយុ៤៦ឆ្នាំគាត់មានជំងឺមហារីកសុដន់ គាត់ស្លាប់នៅពេលតេរេសាអាយុតែ៤ឆ្នាំ។ ឪពុកបានថែរក្សាកូនទាំងអស់ អស់ពីកម្លាំងកាយចិត្ត ឪពុកស្លាប់នៅអាយុ៧១ឆ្នាំដោយមានជំងឺវង្វេងស្មារតី។

ថ្ងៃនេះ ខ្ញុំចង់បង្ហាញថា លូរីស និង ហ្សើលី រស់នៅតាមឧបការគុណរបស់ព្រះជាម្ចាស់ នៅក្នុងអត្ថបទទី១យើងបានស្តាប់ថា **"យើងត្រូវតែពោរពេញដោយសេចក្តីសង្ឃឹមនៅក្នុងជីវិតថ្មីនៅស្ថានបរមសុខ នៅពេលយើងស្លាប់ព្រះយេស៊ូមិនទុកចោលយើង ព្រះយេស៊ូយាងមកដើម្បីទទួលស្វាគមន៍មនុស្សស្លាប់ លុះត្រាតែគេជឿលើព្រះអង្គនិងណែនាំឲ្យមនុស្សដែលមានជីវិតឡើងស្ថានបរមសុខរួមជាមួយព្រះអង្គ នេះជាសេចក្តីសង្ឃឹមរបស់យើងដែលបងប្អូនយកពាក្យទាំងនេះមកដាស់តឿនគ្នាទៅវិញទៅមក"** យើងត្រូវតែបំពេញនៅក្នុងសេចក្តីសង្ឃឹមដោយដឹងថាទោះបីយើងស្លាប់ក៏ដោយ ប្រសិនបើយើងជឿលើព្រះយេស៊ូគ្រីស្តយើងអាចមានជីវិតថ្មីជាមួយព្រះអង្គនៅក្នុងស្ថានបរមសុខ នេះជាមហាសេចក្តីសង្ឃឹមរបស់យើង។ សម្រាប់ ហ្សើលី និង លូរីស គេចូលនៅក្នុងសេចក្តីសង្ឃឹមនេះមែនទែន ដោយសារនៅពេលដែលបាត់បង់កូន៤នាក់ដែលស្លាប់ សម្រាប់ម្តាយ សម្រាប់ឪពុកគឺឈឺចិត្តណាស់។ ប៉ុន្តែ គេដឹងថានៅថ្ងៃណាមួយគេជួបជាមួយកូនគេនៅស្ថានបរមសុខ ពាក្យចុងក្រោយរបស់សន្តី ហ្សើលី គឺ **"ខ្ញុំបិទភ្នែកកូនរបស់ខ្ញុំដោយឈឺចិត្តណាស់ (កូនដែលស្លាប់) ប៉ុន្តែខ្ញុំដឹងថាព្រះជាម្ចាស់ទទួលស្វាគមន៍កូនខ្ញុំ និងនៅពេលអនាគតខ្ញុំជួបកូនខ្ញុំនៅស្ថានបរមសុខរួមជាមួយព្រះជាម្ចាស់"** នេះជាសេចក្តីសង្ឃឹមរបស់យើងលើព្រះជាម្ចាស់ដែលស្រឡាញ់យើងមែនទែន។

គម្ពីរដំណឹងល្អ ណែនាំឲ្យយើងចូលនៅក្នុងគម្រោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់មនុស្សយើង។ ព្រះជាម្ចាស់យាងមកដើម្បីប្រកាសដំណឹងល្អទៅប្រាប់ជនក្រីក្រ **"ព្រះអង្គបានចាត់ខ្ញុំមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថាគេនឹងមានសេរីភាព មនុស្សដែលខ្វាក់នឹងមើលឃើញ ព្រះអង្គមករំដោះយើងពីអំពើបាប ថ្ងៃនេះសេចក្តីនេះទៅជារូបរាងហើយ"**។ ពេលយើងមើលឃើញព្រះយេស៊ូផ្ទាល់ យើងយល់ថាគម្រោងការណ៍របស់ព្រះអង្គ ចាប់ផ្តើមសម្រេចនៅលើផែនដីនេះនៅក្នុងព្រះយេស៊ូផ្ទាល់។ ណែនាំឲ្យជនក្រីក្រស្តាប់ដំណឹងល្អ និងណែនាំមនុស្សយើងទាំងអស់អាចទទួលការសង្គ្រោះ មានន័យថាជីវិតជាប្រចាំ។ នេះ ជាការអស្ចារ្យរបស់ព្រះសហគមន៍និងរបស់ព្រះជាម្ចាស់ដែរដោយសារនេះជាឧបការគុណរបស់ព្រះជាម្ចាស់ តាមរយៈ លូរីស និង ហ្សើលី។ អត្ថបទទាំង២ដែលយើងបានស្តាប់ បង្ហាញអំពីឧបការគុណរបស់ព្រះជាម្ចាស់ អត្ថបទគម្ពីរដំណឹងល្អ **"លើផែនដីនេះព្រះជាម្ចាស់ថែរក្សាការពារយើងឲ្យមានជីវិត និងនៅលើស្ថានបរមសុខព្រះជាម្ចាស់ទន្ទឹងរង់ចាំយើង ដើម្បីមានជីវិតអស់កល្បជានិច្ច"**។

បងប្អូនជាទីស្រឡាញ់ យើងចូលនៅក្នុងសតវត្សទី២១ យើងឃើញសង្គមរបស់យើងដូចជារីកចម្រើនអភិវឌ្ឍន៍យ៉ាងលឿនមែនទែនប៉ុន្តែ ជំនឿរបស់យើងដូចជាខ្សោយទៅៗ។ យើងសុខចិត្តសាងសង់សង្គមថ្មីដែលនៅឆ្ងាយពីព្រះជាម្ចាស់ នៅតែលើទ្រព្យសម្បត្តិ លុយ សុភមង្គលឆា

ប់ៗ ប៉ុន្តែព្រះជាម្ចាស់ដូចជាលែងមានវត្តមាននៅក្នុងសង្គមបច្ចុប្បន្ននេះ។ ពេលយើងឃើញទីក្រុងកំពង់សោម ដែលកំពុងរីកចម្រើនមានការសាងសង់អគាខ្ពស់ៗ មានកាស៊ីណូលាងលុយយ៉ាងច្រើន មានល្បែងស៊ីសងយ៉ាងច្រើន។ នៅជ្រៃធំក៏ដូចគ្នាដែរ មានអគាយ៉ាងច្រើន មានកាស៊ីណូយ៉ាងច្រើន ដើម្បីណែនាំឲ្យមនុស្សយើងមានសេចក្តីសុខ មានសុភមង្គលនៅក្នុងរបៀបផ្សេង។ លូវីស និង ហ្សឺលី អប់រំយើង បំភ្លឺយើង ដើម្បីឲ្យយើងយល់ថាជីវិតដ៏សុខសាន្ត ជីវិតប្រកបដោយសុភមង្គល គឺជាជីវិតដែលយើងយកព្រះជាម្ចាស់ជាមូលដ្ឋានគ្រឹះ ជាអាទិភាពនៅក្នុងជីវិតយើងផ្ទាល់។ ពេលយើងចង់និយាយពីឧបការគុណរបស់ព្រះជាម្ចាស់ មានន័យថាយើងយល់ថាព្រះជាម្ចាស់ជាម្ចាស់នៃជីវិត ព្រះជាម្ចាស់ជាម្ចាស់នៃពិភពលោក ព្រះជាម្ចាស់ជាម្ចាស់នៃប្រវត្តិសាស្រ្ត។ លូវីស និង ហ្សឺលី ទទួលស្គាល់អំពីស្នាមព្រះហស្តរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់គេផ្ទាល់ជាប្រចាំថ្ងៃ ប៉ុន្មានដងប៉ុន្មានសា ហ្សឺលី និយាយថា "**យើងត្រូវផ្ញើជីវិតទៅលើព្រះហស្តរបស់ព្រះជាម្ចាស់ ដោយសារមានតែព្រះជាម្ចាស់ដែលដឹងយ៉ាងច្បាស់លាស់ អំពីសេចក្តីត្រូវការរបស់ខ្ញុំ**"។

គេទទួលស្គាល់អំពីឧបការគុណរបស់ព្រះជាម្ចាស់ នៅក្នុងដំណាក់កាលដ៏សំខាន់នៃជីវិតរបស់គេ នៅពេល លូវីស ធ្វើជាបូជាចារ្យមិនបាន នៅពេល ហ្សឺលី ធ្វើជាបងស្រីមិនបាន នៅពេលនោះគេទៅធ្វើការងារធម្មតា លូវីស គាត់ជាជាងធ្វើនាឡិកា និង ហ្សឺលី គាត់ជាជាងប៉ាក់អាវ។ មានថ្ងៃមួយ គេជួបគ្នានៅលើស្ពានហើយនៅពេលនោះគេមើលមុខគ្នា និងគេចាប់ផ្តើមដូចជាធ្លាក់នៅក្នុងស្នេហា និងក្រោយមកគេរៀបការ។ ប៉ុន្តែ គេអត់ដែលស្គាល់គ្នាទេ ព្រះជាម្ចាស់បានរៀបចំគម្រោងការណ៍ដ៏អស្ចារ្យ ម្នាក់ដែលចង់ធ្វើជាបូជាចារ្យ ម្នាក់ដែលចង់ធ្វើជាបងស្រី ធ្វើមិនបានប៉ុន្តែគេជួបគ្នាទៅជាគ្រួសារមួយ។ នៅពេលនោះ គេយល់ថានេះជាឧបការគុណរបស់ព្រះជាម្ចាស់ ដែលបានថែរក្សាយើងទាំង២ ដែលបានស្រឡាញ់យើងទាំង២ ឲ្យយើងជួបគ្នាដើម្បីបង្កើតគ្រួសារមួយ។ នៅក្នុងជីវិតរបស់គេ គេមានទុក្ខលំបាក គេមានការឈឺចាប់ មានទុក្ខលំបាកធំបំផុតគឺមានកូន៤នាក់ស្លាប់ ប៉ុន្តែមួយទៀតនៅពេល ហ្សឺលី បានទទួលដំណឹងពីគ្រូពេទ្យថាខ្លួននឹងត្រូវស្លាប់៦ខែទៀត ស្របពេលដែលកូនពៅ តេរេសា មានអាយុតែ៤ឆ្នាំ។ ប៉ុន្តែ ទាំង២នាក់មិនធ្លាក់ទឹកចិត្តដោយសារគេដឹងថា នេះជាព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ ព្រះជាម្ចាស់ប្រហែលចង់ឲ្យយើងឈឺចិត្ត ចង់ឲ្យយើងពិបាក ចង់ឲ្យយើងមានទុក្ខលំបាក ក៏ប៉ុន្តែព្រះជាម្ចាស់នៅដើម្បីលើកទឹកចិត្តយើង ដើម្បីផ្តល់កម្លាំងកាយកម្លាំងចិត្តឲ្យយើងទៅមុខទៀត។ ទោះបីកូនខ្ញុំស្លាប់ខ្ញុំដឹងថាព្រះជាម្ចាស់ទទួលស្វាគមន៍ ទោះបីខ្ញុំមានជំងឺដែលព្យាបាលមិនបាន ខ្ញុំដឹងថាព្រះជាម្ចាស់នឹងថែរក្សាខ្ញុំ ដើម្បីរស់នៅជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច និងជួបជាមួយកូនដែល

ស្លាប់ហើយ និងព្រះជាម្ចាស់ថែរក្សាគ្រួសារខ្ញុំ ដើម្បីឲ្យ លូវីស ដែលជាឪពុកអាចថែរក្សាកូនស្រីរបស់យើងឲ្យមានជីវិតដ៏សុខសាន្តតទៅទៀត។

ដូច្នេះ បងប្អូនជាទីស្រឡាញ់នៅក្នុងជីវិតរបស់យើង ជាគ្រួសារយើងមានទុក្ខលំបាក យើងមានបងប្អូនដែលស្លាប់ពីក្មេង យើងមានជំងឺ យើងមានជីវិតក្រីក្រ យើងមានទុក្ខលំបាកនៅក្នុងជីវិតប្រចាំថ្ងៃ។ ប៉ុន្តែ យើងត្រូវការដឹងថាព្រះជាម្ចាស់គង់នៅជាមួយយើង ព្រះជាម្ចាស់អត់ដែលលះបង់ចោលយើង ឲ្យយើងផ្ញើជីវិតទៅលើឧបការគុណរបស់ព្រះជាម្ចាស់ដូច លូវីស និង ហ្សេលី ណែនាំឲ្យជីវិតរបស់យើងអាចទៅមុខ រកឃើញសេចក្តីសង្ឃឹមសម្រាប់កូនយើង សម្រាប់គ្រួសារយើងសម្រាប់ថ្ងៃអនាគត នេះជាការអស្ចារ្យដែលព្រះជាម្ចាស់បានរៀបចំសម្រាប់ជីវិតយើងផ្ទាល់។ ថ្ងៃនេះ ខ្ញុំសូមអញ្ជើញគ្រួសារនីមួយៗដែលបន្តិចទៀតអធិដ្ឋានទៅសន្ត លូវីស និងសន្តី ហ្សេលី សូមការពារថែរក្សាសេចក្តីសង្ឃឹមទៅលើព្រះជាម្ចាស់ និងទុកចិត្តទៅលើព្រះជាម្ចាស់ដោយដឹងថា ជីវិតរបស់យើងមានអំណរសប្បាយក្តី ពិបាកក្តី ទុក្ខលំបាកក្តី ព្រះជាម្ចាស់គង់នៅ និងដោយសារជំនឿរបស់យើង យើងអាចទៅមុខទៀតនៅលើផែនដីនេះ។

ពិតមែន ព្រះជាម្ចាស់យាងមកដើម្បីប្រាប់ដំណឹងល្អដល់ជនក្រីក្រ និងដើម្បីសម្តែងផ្ទាំងធម៌មេត្តាករុណាឲ្យយើងរស់នៅក្នុងព្រះហឫទ័យមេត្តាករុណា ដូចសន្តី ហ្សេលី និងសន្ត លូវីស បានរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ជាមួយកូនរបស់គាត់ឲ្យស្គាល់ព្រះជាម្ចាស់ ឲ្យចេះអធិដ្ឋាន ឲ្យចូលអភិបូជា ឲ្យគោរពអ្នកដទៃ ឲ្យចេះបម្រើគ្នាទៅវិញទៅមក ណែនាំឲ្យគ្រួសារនេះពោរពេញដោយសេចក្តីសុខ ដោយសាររស់នៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះជាម្ចាស់ជានិច្ច។ ជយោសន្ត លូវីស ជយោសន្តី ហ្សេលី ជយោព្រះជាម្ចាស់។ អាម៉ែន៕